ឈ្មោះ : សេក ធីតា
ដេប៉ាតឺម៉ង់ : អក្សរសាស្ត្រខ្មែរ ឆ្នាំទី៣

<u>ប្រធានបទ៖</u>

ហេតុអ្វីបានជាយុវជនត្រូវយល់ដឹងអំពីសេវាធានារ៉ាប់រងអាយុជីវិត? តើសេវាធានារ៉ាប់រងនេះមានសារប្រយោជន៍អ្វីខ្លះសម្រាប់ក្រុមគ្រួសារ និងសង្គមជាតិ?

<u>សេចក្តីអធិប្បាយ</u>

សង្គមជាតិមួយមានការរីកចម្រើន លូតលាស់លើគ្រប់វិស័យ សុទ្ធតែបានប្រសូត្រចេញមកពីការចូលរួមអភិវឌ្ឍយ៉ាងសស្រាក់សស្រាំរបស់មនុស្សនៅក្នុងសង្គមនោះ ។ ក្នុងចំណោមនោះ យុវជនក៏ជាចំណែកមួយយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍសង្គមជាតិឲ្យមានការរីកចម្រើនដែលពុំអាចខ្វះបានឡើយ ។ រាល់បញ្ហាទាំងឡាយនៅក្នុងសង្គម យុវជនដែលជាសសរទ្រូងនៃប្រទេសជាតិ គួរតែយល់ដឹងឲ្យបានច្រើនមិនថាបញ្ហាវប្បធម៌ បញ្ហាសង្គមទូទៅ កិច្ចអភិវឌ្ឍសហគមន៍ ការរៀបចំផែនការអនាគត ការផ្តល់ជូននូវសេវាធានារ៉ាប់រងអាយុជីវិតជាដើម គឺសុទ្ធតែមានសារសំខាន់ និងផ្តល់នូវសារប្រយោជន៍សម្រាប់សង្គមមនុស្សទាំងអស់ ជាពិសេសនោះគឺការស្វែងយល់ពីសេវាធានារ៉ាប់រងអាយុជីវិត ដើម្បីមានភាពងាយស្រួលក្នុងការរៀបចំផែនការអនាគតឲ្យកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។

ហេតុអ្វីបានជាយុវជនត្រូវយល់ដឹងអំពីសេវាធានារ៉ាប់រងអាយុជីវិត? តើសេវាធានារ៉ាប់រងនេះមានសារប្រយោជន៍អ្វីខ្លះសម្រាប់ក្រុមគ្រួសារ និងសង្គមជាតិ?

ជាបឋមមុននឹងឈានទៅដល់ការបកស្រាយប្រធានខាងលើឲ្យបានក្បោះក្បាយ យើងគប្បីគួរស្វែងយល់ពីអត្ថន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិន។ នៅក្នុងបរិបទសង្គម វប្បធម៌ និងនយោបាយ យុវជន បសំដៅទៅលើបុរស ឬ ស្ត្រី មានអាយុពី១៥ឆ្នាំ ដល់៣០ឆ្នាំ នៅលីវ ឬរៀបការហើយ ពោលគឺជាប្រជាជនសកម្មក្នុងការចូលរួមអភិវឌ្ឍគ្រួសារ និងសង្គមជាតិ។ ចំណែកឯ ធានារ៉ាប់រងអាយុជីវិតបើយោងការឲ្យនិយមន័យរបស់ក្រុមហ៊ុនព្រូដិនសល មានន័យថាជាមធ្យោបាយក្នុងការផ្តល់ជូនខ្លួនឯងនូវការការពារហិរញ្ញវត្ថុសម្រាប់មនុស្សជាទីស្រឡាញ់ ក្នុងករណីដែលមានហេតុការណ៍អកុសលកើតឡើងចំពោះជីវិតរបស់យើង ពោលគឺជាការរក្សាប្រាក់បម្រុងទុកសម្រាប់គ្រួសារ ដើម្បីបង្ការក្នុងករណីដែលមានគ្រោះអាក្រក់កើតឡើងដោយមិនបានដឹងមុនទៅលើអាយុជីវិតរបស់មនុស្សម្នាក់។ ដូច្នេះ យោងទៅតាមន័យរបស់ពាក្យគន្លឹះខាងលើ ទស្សនៈរបស់ប្រធានចង់បង្ហាញថាយុវជន ដែលជាប្រជាជនសកម្មរបស់សង្គមត្រូវតែយល់ដឹងពីសេវាធានារ៉ាប់រងអាយុជីវិតឲ្យបានច្រើន ដោយសេវាធានារ៉ាប់រងអាយុជីវិតនេះបានផ្តល់នូវសារប្រយោជន៍ជាច្រើនដល់សង្គមមនុស្ស ដើម្បីផ្តល់ភាពងាយស្រួលក្នុងការរៀបចំផែនការជីវិតពួកគេឲ្យបានត្រឹមត្រូវប្រកបដោយចីរភាព។

ជាការពិតណាស់ យុវជនត្រូវតែខិតខំសិក្សារៀនសូត្រ ស្វែងយល់ពីបញ្ហាផ្សេងៗ ដែលកើត

មាននៅក្នុងសង្គម ជាពិសេសនោះគឺការស្វែងយល់ពីសេវាធានារ៉ាប់រងអាយុជីវិត ព្រោះយុវជនជាទំពាំងស្នងឫស្សី ជាសសរទ្រូងនៃប្រទេសជាតិ ជាអ្នកត្រូវដែលទទួលយកចំណេះដឹង ជំនាញផ្សេងៗបទពិសោធន៍ពីអ្នកជំនាន់មុន ហើយយកចំណេះទាំងនោះទៅចែករំលែកដល់មនុស្សនៅក្នុងសង្គមដើម្បីចូលរួមលើកស្ទួយកាឬអភិវឌ្ឍប្រទេសជាតិឲ្យកាន់ការរីកចម្រើន។ ជាងនេះទៀតយុវជនជាកម្លាំងចលករមួយយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យទាំងវិស័យសេដ្ឋកិច្ច វស័យកម្មសិកម្ម ឧស្សាហកម្ម ទេសចរណ៍ជាដើម ដែលគ្រប់វិស័យមិនខ្វះយុវជនបានឡើយ។ យុវជនជាទីពុំនាក់ ជាបង្គោលរបស់គ្រួសារ និងសង្គមជាតិទាំងមូល ក្នុងទិសដៅនេះយុវជនតែងតែមានចក្ខុវិស័យវែងឆ្ងាយ និងមានក្តីស្រមៃសម្រាប់ពេលអនាគតរៀងខ្លួនៗ ដើម្បីសម្រេចនូវក្តីស្រមៃទាំងនោះ ពួកគេត្រូវតែមានគម្រោងផែនការអនាគតយ៉ាងត្រឹមត្រូវ ហើយប្រសិនបើយុវជនយល់ដឹងពីសេវាធានារ៉ាប់រងនេះបានកាន់ តែច្រើននោះ វានឹងមានភាពងាយស្រួលក្នុងការរៀបចំផែនការសម្រាប់ជីវិតពួកគេឲ្យភាពល្អប្រសើរ ព្រោះសេវាធានារ៉ាប់រងនេះផ្តល់ជូននូវទំនុកចិត្ត និងមានកិច្ចសន្យាធានាជូនយ៉ាងត្រឹមត្រូវ និងស្របច្បាប់សង្គម។ ក្នុងន័យនេះដែរយុវជនមានតួនាទីយ៉ាងសំខាន់នៅក្នុងគ្រួសារ ព្រមទាំងសង្គមជាតិព្រោះពួកគេត្រូវធានារ៉ាប់រងអនាគតរបស់ពួកគេ និងក្រុមគ្រួសារ ថែមទាំងលើកតម្កើងគ្រប់វិស័យទាំងអស់ឲ្យមានការរីកចម្រើនផងដែរ។ មិនត្រឹមតែប៉ុណ្ណោះយុវជន ជាអ្នកចូលរួមផ្តួចផ្តើមគំនិតអភិវឌ្ឍសង្គមជាអ្នកដែលមានគំនិតយ៉ាងសម្បូរបែបក្នុងការបង្កើតថ្មី ដូច្នេះកាលណាយុវជនយល់ដឹងពីសេវាធានារ៉ាប់រងអាយុជីវិត ពួកគេនឹងយកចំណេះដឹងនេះទៅផ្សព្វផ្សាយនៅក្នុងសង្គម ធ្វើឲ្យមនុស្សក្នុងសង្គមនោះមានការយល់ដឹងពីសេវាធានារ៉ាប់រងនេះ និងសារប្រយោជន៍របស់វាផងដែរ។ ជាក់ស្តែងក្នុងសម័យបច្ចុប្បន្ន រដ្ឋាភិបាលបានជំរុញលើកចិត្តឲ្យ យុវជនបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការងារសង្គមផ្សេងៗ ព្រោះយុវជនជាធនធានមនុស្សដែលពុំអាចខ្វះបានឡើយក្នុងការអភិវឌ្ឍសង្គមជាតិមានដំណើរការទៅបានយ៉ាងរលូន ។ ក្រៅពីនេះយើងឃើញមានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតជាច្រើនដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជាយើង នេះសបញ្ជាក់ឲ្យឃើញថាសេវាធានារ៉ាប់រងអាយុជីវិតនេះពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់សង្គមខ្មែរ ហើយយុវជន ក៏ត្រូវតែយកចិត្តទុកស្វែងយល់ឲ្យបានច្រើនពីសេវានេះផងដែរ។ កាលណាយុវជនមានការយល់ដឹងកាន់តែច្រើន សង្គមគ្រួសារក៏រស់នៅប្រកបដោយសុភមង្គល ហើយសង្គមជាតិក៏មានការរីកចម្រើន។ លើសពីនេះទៅទៀតសេវាធានារ៉ាប់រងអាយុជីវិតពិតជាមានពិតមានគុណសម្បត្តិយ៉ាងច្រើនក្រៃលែង សម្រាប់យុវជនផ្ទាល់ ក៏ដូចជាក្រុមគ្រសារ និងសង្គមជាតិទាំងមូល ព្រោះយើងពុំអាចដឹងមុនទេថានឹងមានរឿងអ្វីកើតឡើងចំពោះយើងជួនកាលវាជារឿងល្អ ជួនកាលវាជារឿងអាក្រក់។ ក្នុងន័យនេះឃើញថា សេវាធានារ៉ាប់រងអាយុជីវិតពិតបានផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនដល់គ្រួសារដូចជា ផ្តល់ជូននូវទំនុកចិត្ត និងភាពកក់ក្តៅជូនមនុស្សនៅក្នុងគ្រួសារ ព្រមទាំងជួយសម្រេចក្តីបំណងរបស់ពួកគេ នាំឲ្យគ្រួសារពោរពេញទៅដោយសុភមង្គល។ម្យ៉ាងវិញទៀត វាជួយការពារហិរញ្ញវត្ថុ ពោលគឺជួយរក្សាប្រាក់បម្រុងទុកសម្រាប់គ្រួសារក្នុងករណីមានរឿងអកុសលកើតឡើងចំពោះមនុស្សម្នាក់នៅក្នុងគ្រួសារ ឬមិនមានរឿងអ្វីកើតឡើងក៏

ដោយ និងជួយរក្សាប្រាក់បម្រុងទុកសម្រាប់សម្រេចក្តីសុបិន្តពួកគេនាពេលអនាគត ដូចជាសម្រាប់បង់ថ្លៃការសិក្សាកូនៗពួកគេជាដើម។ ដោយហេតុថា សេវាធានារ៉ាប់រងអាយុជីវិតនេះ ផ្តល់នូវគម្រោងផែនការយ៉ាងច្បាស់លាស់សម្រាប់ខ្លួនឯង និងក្រុមគ្រួសារ ដោយការទទួលយកការផ្តល់ជូនសេវាធានារ៉ាប់រងអាយុជីវិតពីក្រុមហ៊ុនណាមួយ។ ជាក់ស្តែងដូចជាក្រុមហ៊ុនព្រូដេនសល ដែលជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដ៏ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជូនទំនុកចិត្តដល់អតិថិជនរបស់ខ្លួន ដោយការផ្តល់សេវាធានារ៉ាប់រងមួយយ៉ាងសមស្រប នូវការការពារហិរញ្ញវត្ថុក្នុងរយៈពេលវែង ដែលមានរយៈពេល១០ឆ្នាំ ១២ឆ្នាំ ១៥ឆ្នាំ ឬច្រើនជាងនេះ។ ការធានារ៉ាប់រងនេះ គឺតាមរយៈការបង់ថ្លៃសងប្រាក់ដល់ក្រុមគ្រួសារទៅតាមចំនួនទឹកប្រាក់ដែលមាននៅក្នុងកិច្ចសន្យា ទោះក្នុងករណីដែលមេគ្រួសារមិនមានជីវិតរស់នៅ ដោយសារការជួបគ្រោះថ្នាក់ផ្សេងៗ ឬបាត់បង់ជីវិតដោយសារជម្ងឺក៏ដោយ។ ហើយក្រុមហ៊ុនមានធានារ៉ាប់រងលើការរក្សាប្រាក់បម្រុង សម្រាប់សម្រេចនូវក្តីសុបិនរបស់ពួកនៅពេលអនាគតឲ្យក្លាយជាការពិតដូចជាសម្រាប់ការសិក្សារបស់កូនៗ ផែនការចូលនិវត្តន៍ ឬផែនការចាំបាច់ដទៃទៀត។ ជាងនេះទៀតសោតក្រុមហ៊ុនព្រូដិនសល នៅតែធានារ៉ាប់រងដូចដើម ទោះបីជាគ្មានគ្រោះថ្នាក់ផ្សេងៗ ឬបញ្ហាអ្វីកើតឡើងក៏ដោយ គឺក្រុមហ៊ុនសងប្រាក់មកឲ្យគ្រួសារវិញតាមលំហូរនៃចំនួនសាច់ប្រាក់របស់ពួកគេ។ សេវាធានារ៉ាប់រងអាយុជីវិតមិនត្រឹមតែផ្តល់ផលប្រយោជន៍ចំពោះគ្រួសារប៉ុណ្ណោះទេ ថែមទាំងផ្តល់ប្រយោជន៍យ៉ាងច្រើនដល់សង្គមជាតិទៀតផង។ ផលប្រយោជន៍ទាំងនោះរួមមាន សង្គមជាតិមានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដ៏មានទំនុកចិត្ត និងមានការរីកចម្រើនលើគ្រប់វិស័យ ព្រោះប្រជាជនរស់នៅដោយមានសុភមង្គល ប្រាក់ចំណូលចំណាយមានការកំណត់ច្បាស់លាស់ នាំឲ្យសេដ្ឋកិច្ចគ្រួសារមានការរីកចម្រើន ជាហេតុនាំឲ្យប្រទេសជាតិមានការអភិវឌ្ឍឥតឈប់ឈរ។ ម្យ៉ាងវិញសង្គមទាំងមូលលែងមានការព្រួយបារម្ភចំពោះកំណើនប្រជាជន ព្រោះគ្រួសារនីមួយៗមានផែនការច្បាស់លាស់សម្រាប់គ្រួសារខ្លួនរួចទៅហើយ ដោយពុំចាំព្រួយខ្លាចក្រែងប្រជាជនពុំបានទទួលការសិក្សាអប់រំ ខ្លាចប្រជាជនគ្មានការងារធ្វើនោះទេ។ មួយវិញទៀតវាជួយកាត់បន្ថយភាពក្រីក្រ និងការចំណាកស្រុករបស់ប្រជាជនផងដែរ ព្រោះប្រជាជនមានការងារធ្វើ មានការប្រាក់ចំណូលចំណាយប្រជចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំច្បាស់លាស់។ ទាំងនេះគឺជាមោទកភាពមួយរបស់សង្គម ដែលពោរពេញទៅដោយមនុស្សមានការងារធ្វើ មនុស្សមានការអប់រំ មានការសិក្សាល្អ ដែលនាំឲ្យសង្គមជាតិទាំងមូលពោរពេញទៅសុខសន្តិភាព និងការអភិវឌ្ឍ។ បន្ថែមលើនេះទៀតកេរ្តិ៍ឈ្មោះនៃប្រទេសយើងក្នុងនាមជាប្រទេសដែលមានសន្តិភាព សេដ្ឋកិច្ចមានរីកចម្រើន នឹងមានភាពល្បីសុះសាយទៅដល់ប្រទេសជិតខាង ដែលធ្វើឲ្យប្រទេសទាំងនោះ មានការជឿជាក់លើប្រទេសយើង ជាហេតុនាំសង្គមជាតិយើងមានការបណ្តាក់ទុន និងដៃគូសហប្រតិបត្តិការកាន់តែច្រើន ប្រជាជនក៏កាន់តែមានការងារធ្វើច្រើនជាងមុនទៀតផង។ ជាឧទាហរណ៍នៅក្នុងសង្គមនៃប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្នក្រោមការដឹកនាំរបស់ រដ្ឋាភិបាលដ៏ឆ្នើម ឃើញថាមានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតជាច្រើន ពិសេសទៀតនោះគឺមានក្រុមហ៊ុនព្រូដិនសល ក្រុមហ៊ុនឈានមុខគេនៅកម្ពុជា

ដែលបានផ្តល់នូវសេវាធានារ៉ាប់រងអាយុជីវិតជូនប្រជាជនយ៉ាងមានទំនុកចិត្តខ្ពស់ ជាហេតុនាំឲ្យប្រទេសជាតិមានមានរីកចម្រើនឥតឈរលើគ្រប់វិស័យ ជាពិសេសនោះគឺវិស័យសេដ្ឋកិច្ចជាតិ ហើយប្រជាជនរស់នៅដោយភាពជឿជាក់យ៉ាងមានទំនុកចិត្តប្រកបសេចក្តីសុខក្សេមក្សាន្ត និងសុខសន្តិភាព។

សរុបសេចក្តីមកយុវជនដែលជាសសរទ្រូងនៃប្រទេសជាតិ ជាទីពុំនាក់របស់គ្រួសារ និងសង្គមជាតិ គួរតែយល់ដឹងពីសេវាធានារ៉ាប់រងអាយុជីវិតឲ្យបានច្រើន ដើម្បីយកការយល់ដឹងទាំងទៅ អភិវឌ្ឍគ្រួសារនិងសង្គមជាតិ។ ជាងនេះទៀតសោតយើងឃើញថាសេវាធានារ៉ាប់រងអាយុជីវិតពិតមានសារសំខាន់ខ្លាំងណាស់សម្រាប់សង្គមមនុស្ស ព្រមទាំងបានផ្តល់នូវផលប្រយោជន៍ជាច្រើនក្រៃលែងដល់យុវជន គ្រួសារ និងសង្គមជាតិទាំងមូល។

ឆ្លងតាមកាបកស្រាយ និងឧទាហរណ៍ខាងលើ ឃើញថាទស្សនៈរបស់ប្រធានខាងលើពិតជាខ្លឹមសារយ៉ាងល្អត្រឹមត្រូវ ប្រកបដោយភាពសមហេតុផលស្របទៅតាមបរិបទសង្គមនាពេលបច្ចុប្បន្នដែលជាសម័យកាលមួយសង្គមមានការរីកចម្រើនខ្លាំង។ ការដែលបង្ហាញពីសារសំខាន់របស់យុជនក្នុងការស្វែងយល់ពីសេវាធានារ៉ាប់រងអាយុជីវិត និងបង្ហាញពីសារប្រយោជន៍របស់សេវាធានារ៉ាប់រងនេះ គឺជាប្រធានបទមួយយ៉ាងសំខាន់ដែលប្រជាជនគ្រប់ស្រទាប់វណ្ណៈគួរយកចិត្តដាក់សិក្សាស្វែងយល់ឲ្យបានច្រើន។ ដូច្នេះក្នុងនាមយើងជាយុវជនត្រូវតែខិតខំសិក្សារៀនសូត្រ និងស្វែងយល់ពីបញ្ហានានានៅក្នុងសង្គម ព្រមទាំងសេវាធានារ៉ាប់រងអាយុជីវិត ដើម្បីបង្កើនចំណេះដឹង សមត្ថភាពផ្ទាល់ខ្លួន និងរស់នៅក្នុងជីវិតប្រចាំថ្ងៃឲ្យកាន់តែល្អប្រសើរស្របទៅតាមការរីកចម្រើនរបស់សង្គម ព្រមទាំងចូលរួមចំណែកផ្តួចផ្តើមគំនិតក្នុងអភិវឌ្ឍសង្គមឲ្យកាន់តែមានការរីកចម្រើនលើគ្រប់វិស័យផងដែរ។